ក. អាករលើការស្នាក់នៅត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្តត់ផ្គង់សេវាស្នាក់នៅ ។ ការផ្តត់ផ្គង់សេវាស្នាក់នៅ គឺជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញ

វិក្កយបត្រ ឬជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះ ត្រូវបានចេញមុនពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាង ត្រូវចេញវិក្កយបត្រ ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្កយបត្រអាករ លើការស្នាក់នៅយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយពីការបំពេញសេវាស្នាក់នៅត្រូវបញ្ចប់ឬក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើង មុនការបំពេញសេវាលើការស្នាក់នៅ ។

ខ. ក្នុងករណីសេវាលើការស្នាក់នៅ ត្រូវបានផ្តត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់ គឺជាពេលដែលសេវាផ្គត់ផ្គង់ត្រូវបានបំពេញរួចរាល់ ។

ប្រការ ៥.-

បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រូវយកមកអនុវត្តចំពោះអាករលើការស្នាក់នៅនេះ។

ប្រការ ៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៦ សហវ.

សារាចរណែនាំ

ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ខេត្ត ក្រុងឆ្នាំ ២០០៦

យោងសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦ ដូចតទៅ ÷

I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬ ផលទុន ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណូលថវិការបស់ខេត្ត ក្រុង សាមីដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - \+ លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - \+ ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - \+ ព៌ន៍ស្មានលើការវិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - \+ ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  - \+ ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។

- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ សំរាប់ថវិកាខេត្ត ក្រុង ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូលសរុប ទៅតាមតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មកជាមួយនេះ ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិកាខេត្ត ក្រុង ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគំរោងចំណូល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេស ដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង រួចហើយនោះ ។

II. ការរៀបចំចំណាយថវិកា

3. ខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណាយសំរាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណា ដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។ របៀបគិតគូរនូវតំរូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗដោយច្បាស់លាស់ និងដោយផ្អែកទៅ លើកត្តានានា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះ ដូចជា តារាងបុគ្គលិក បញ្ជីផាត់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា... ។ ចំពោះសកម្មភាពមួយចំនួនទាមទារអោយមានបង្កើតធម្មនិយាមសមស្រប ដូចជា ចំណាយជួសជុលក្នុងមួយម៉ែត្រការ៉េ ចំនួនទឹកប្រាក់ចាំបាច់ សំរាប់ផ្ទៃក្រឡាណាមួយ ការប្រើប្រាស់គ្រឿងចក្រគិតជា ប្រេងឥន្ធនៈ ការសិក្សាវិច័យនៃសំបកកង់រថយន្តគិតជាគីឡូម៉ែត្រជាដើម ។ ចំពោះសម្ភារៈបរិក្ខារដែលប្រើប្រាស់ជាប្រចាំ ត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្តាឆ្នាំកន្លងមក ។ ចំណែកឯ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងនិងក្រៅប្រទេស) និងប្រាក់ឈ្នួលផ្ទះ ទឹកភ្លើងរបស់អភិបាល អភិបាលរងគ្រប់ខេត្ត ក្រុងត្រូវអនុវត្តផ្អែកលើមូលដ្ឋានអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការទីប្រឹក្សាព្រមទាំងមន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត ក្រុង ត្រូវបានសរុបនៅក្នុងតារាង ឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មកជាមួយនេះ ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយ តាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសមហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

5. សារាចរណែនាំនេះ ក៏មានភ្ជាប់ជាមួយនូវសលាកប័ត្រគំរូមួយចំនួនសំរាប់បំពេញនូវឥណទាន ដែលត្រូវស្នើសុំទៅតាមមុខចំណាយនីមួយៗ ។ សលាកប័ត្រទាំងអស់នេះ ត្រូវបានអង្គភាពនានារបស់ខេត្ត ក្រុង ប្រើប្រាស់សំរាប់ផ្តល់នូវពត៌មានបន្ថែម ទៅលើការស្នើសុំឥណទានរបស់ខ្លួន ។

II.1 ការរៀបចំគំរោងចំណាយចរន្ត

6. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ៖

ប្រភេទ ១ : មធ្យោបាយសេវា

ជំពូក១០ : ប្រាក់បៀវត្ស និង ប្រាក់បំណាច់

7. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជា

ចេញដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ មន្ត្រីរាជការដែលមានដាក់ស្តែងក្នុងឆ្នាំ ២០០៥ មន្ត្រីរាជការដែលចូលនិវត្តន៍ត្រូវផ្ទេរចេញពីក្របខ័ណ្ឌ និងមន្ត្រីមរណៈដែលត្រូវកាត់បន្ថយពីអង្គភាពរបស់ខ្លួន នៅឆ្នាំ ២០០៦ ខាងមុខនេះរាជរដ្ឋាភិបាលនឹងបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ១៥ភាគរយ ដែលនឹងប្រើឥណទាននៃមូលនិធិបម្រុង។ ចំពោះគំរោង ចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្ដែត និងគំរោងចំណាយអំពីលាភការភ្នាក់ ងារជាប់កិច្ចសន្យា គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌឥណទានដែលបានពិភាក្សា រួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក. បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន

8. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមនិវាទខេត្ត ក្រុង ត្រូវបូកសរុបនៅក្នុងសលាកប័ត្រ១ ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត ក្រុងមាន ។

9. សលាកប័ត្រ១នេះ គឺសំរាប់សរុបបុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាង ប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

10. ខេត្ត ក្រុងត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខ័ណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមនិវាទរបស់ខ្លួន ។

ខ. ការជ្រើសរើសបុគ្គលិកថ្មី

11. អភិបាលខេត្ត ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌនៃថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់ភ្នាក់ងារសាធារណៈទាំងអស់ ។ ខេត្ត ក្រុងអាចសំរេចជ្រើសរើសអោយចូលធ្វើការចំពោះបុគ្គលិកប្រភេទ "គ" និង"ឃ" ក្នុងករណីដែលចាំបាច់បំផុតបន្ទាប់ពីបានប្រើប្រាស់អោយអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ប្រការនេះគឺជាគោលការណ៍រួមតែប៉ុណ្ណោះ។ បច្ចុប្បន្នក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងដំណើរការ កែទំរង់រដ្ឋបាលសាធារណៈនិងធ្វើវិចារណកម្មលើចំនួនក្របខ័ណ្ឌមន្ត្រីរាជការនោះ ខេត្ត ក្រុងមិនត្រូវបានអនុញ្ញាតអោយជ្រើសរើសបុគ្គលិកថ្មីទេ ។

ជំពូក១១ : ដំណើរការរដ្ឋបាល សម្ភារៈនិងការជួសជុលតូច

12. ជំពូក១១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃបំផុត ក្នុងឆ្នាំ២០០៦ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈចំណាយឥណទានផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិត៩៣ភាគរយនៃឆ្នាំ ២០០៥ តែប៉ុណ្ណោះ ។ ដោយឡែកការកាត់បន្ថយចំនួន ៧ភាគរយនេះ គឺបង្ហាញអោយឃើញអំពីភាពហ្មឺងម៉ាត់របស់រាជរដ្ឋាភិបាលក្នុងការសន្សំសំចៃថវិកាទុកសំរាប់ដោះរំលស់បំណុលសាច់ប្រាក់កកស្ទះនៅធនាគារជាតិ និងសំរាប់បង្កើនចំណាយវិនិយោគសាធារណៈនិងចំណាយលើការថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសផ្លូវស្ពាន និងប្រព័ន្ធស្រោចស្រព។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត ក្រុង (ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ក្នុងការរៀបចំមូលដ្ឋានសំភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត ក្រុងរបស់ក្រសួងមហាផ្ទៃ ខេត្ត ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយអាទិភាពនៃគំរោងចំណាយលំអិតអំពីការងារជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។សលាកបត្រយុត្តិការដែលមានខាងក្រោមនេះ សំរាប់បង្ហាញនូវខ្ទង់ចំណាយសំខាន់ៗ ក្នុងជំពូក១១ របស់អង្គភាពនីមួយៗដែលមានការពាក់ព័ន្ធ ។

- អសង្ហារិម (សលាកបត្រ២) : ឥណទានត្រូវបានបែងចែកតាមកន្លែងដែលប្រើប្រាស់គ្រឿងអសង្ហារិម ដូចជា កន្លែងរដ្ឋបាល ឬនិវាសនដ្ឋាន និងតាមប្រភេទចំណាយ ដូចជាការថែទាំ ការប្រើប្រាស់ទឹក អគ្គិសនីជាដើម ។
- ចលនវត្ថុ សម្ភារៈ (សលាកបត្រ៣) : គប្បីបែងចែកដាច់ពីគ្នារវាងការទិញនិងការថែទាំ ។ ចំពោះសម្ភារៈការិយាល័យមានខ្ទង់មួយសំរាប់បំពេញក្នុងសលាកបត្រនេះ ។
- រថយន្ត (សលាកបត្រ៤) : ជាទូទៅ ចំណាយលើការប្រើប្រាស់និងថែទាំរថយន្ត មានទំហំធំធេងណាស់បើប្រៀបធៀបនឹងប្រភេទចំណាយឯទៀត ។ ដូច្នេះអង្គភាពនីមួយៗត្រូវគិតគូរយ៉ាងណា ដើម្បីខ្ទប់ចំណាយនេះកុំអោយលើសពីកំរិតដែលសមស្រប ។ ការធ្វើយុត្តិកម្មឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងត្រូវផ្អែកទៅលើគុណភាពរថយន្ត ម៉ាករថយន្ត ផ្លាកលេខ ឆ្នាំទិញ ចម្ងាយផ្លូវដែលបានបើកបរគិតជាគីឡូម៉ែត្រ រីឯការគ្រោងឥណទានអនុញ្ញាតអោយគ្រោង បានចំពោះតែរថយន្តស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋតែប៉ុណ្ណោះ ។ ដោយហេតុនេះហើយត្រូវបែងចែកឥណទានដែលស្នើសុំ ទៅតាមឥណទានសំរាប់ការថែទាំ សំរាប់ប្រេងឥន្ធនៈ និងសំរាប់ប្រេងរំអិល ។
- សោហ៊ុយធ្វើដំណើរ (សលាកបត្រ៥) : គឺជាប្រាក់សំរាប់ធ្វើដំណើរ របស់មន្ត្រីរាជការចេញទៅបំពេញបេសកកម្ម ។ ប្រការនេះ គឺត្រូវបែងចែកអោយដាច់ពីគ្នាទៅតាមប្រភេទបេសកកម្ម ដូចដែលបានចែងក្នុងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ មេសា ឆ្នាំ ២០០៤ ។
- ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ដូចជាចំណាយបំភ្លឺសាធារណៈ ការប្រមូលសំរាម ថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ ប្រឡាយ លូទឹកជាដើម ត្រូវមានគំរោងលំអិតសំរាប់មុខសញ្ញានីមួយៗ និងត្រូវបញ្ជាក់នូវទីតាំង ភូមិ ឃុំ សង្កាត់ និងស្រុក ខណ្ឌអោយបានច្បាស់លាស់ ។
- ចំណាយទទួលភ្ញៀវ ទស្សនៈកិច្ចនិងប្រជុំ ត្រូវគ្រោងអោយស្ថិតនៅក្នុងកំរិតមួយសមស្របដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់និងមិនធ្វើអោយបាត់តុល្យភាពថវិកា ។ ចំពោះខេត្ត ក្រុង ដែលទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ ត្រូវគ្រោងចំណាយប្រភេទនេះក្នុងកំរិតទាបបំផុត ។

13. សលាកបត្រទាំងប៉ុន្មាននេះ មិនអាចប្រើប្រាស់ជាលិខិតយុត្តិការចាំបាច់បានគ្រប់គ្រាន់ទេ ដោយគ្រាន់តែធ្វើជាមូលដ្ឋានសំរាប់រៀបចំគំរោងថវិកាអោយស្ថិតក្នុងកំរិតមួយសមស្រប នៅក្នុងការគិតគូរនិងឆ្លើយតបទៅនឹងគោលដៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈតែប៉ុណ្ណោះ ។ សលាកបត្រមានច្រើនប្រភេទបែបនេះ គឺសំរាប់ធានាអោយបាននូវសុពលភាពនៃគំរោងចំណាយ និងភ្ជាប់ជាមួយនូវសំណុំឯកសារ ដើម្បីបង្ហាញនូវថវិកាជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

14. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀត ខេត្ត ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គីសនី ទឹក ខេត្ត ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវក្នុងឆ្នាំ និងការសងបំណុល ក្នុងករណីដែលខេត្ត ក្រុងគ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងថវិការបស់ខេត្ត ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត ក្រុងដោយស្វ័យប្រវត្តិ ។

15. ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង (ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ខេត្ត ក្រុងត្រូវគ្រោងឥណទានដោយលំអិតតាមវាក្យខណ្ឌនីមួយៗ ហើយក្នុងវាក្យខណ្ឌនីមួយៗ ក៏ត្រូវមានគំរោងលំអិតតាមការដ្ឋាននីមួយៗដោយមានបញ្ជាក់អំពីបញ្ជីថ្លៃតម្លៃ និងទីតាំងច្បាស់លាស់សំរាប់យកមកពិភាក្សាសំរេចជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលតែមួយនៃការពិភាក្សាថវិកាប្រចាំឆ្នាំ ។

ជំពូក១២ : ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល

16. ចំណាយក្នុងជំពូកនេះសំរាប់ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល ដែលខេត្ត ក្រុងបង្កើតឡើងហើយកំរៃសេវាសាធារណៈ ដែលទទួលបានពុំអាចរ៉ាប់រងបាននូវរាល់ការចំណាយចាំបាច់ ។

ប្រភេទ ៣ : ចំណាយអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

17. ចំពោះចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានបា្ញក់ចាក់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

ប្រភេទ ៤ : ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក

18. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត ។ សំរាប់ឆ្នាំថវិកា២០០៦ប្រភេទឥណទាន គឺអនុញ្ញាតអោយគ្រោងចំនួន ៣ ភាគរយ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលជាតំរូវការចំណាយចៃដន្យកើតមានឡើងដោយយថាហេតុ ។

19. ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុននិងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

20. គំរោងវិនិយោគរបស់ខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការ អោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុង មានចំណូលជាមូលធនផ្ទៃក្នុងខេត្ត ក្រុងផ្ទាល់ ។

– ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬ គំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត ក្រុង ។ ទន្ទឹមនឹងនេះក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

III. គំរោងចំណូល ចំណាយសរុប

21. គំរោងចំណូល ចំណាយថវិការបស់ខេត្ត ក្រុងនីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង ។ គំរោងចំណូលចំណាយនេះ ត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ហើយត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាមួយ ដែលមានប្រភពធនធានរួមផ្សំឡើងដោយការឧបត្ថម្ភមានកំរិតកំណត់ពីថវិការដ្ឋ និងលទ្ធភាពពិតប្រាកដនៃការប្រមូលចំណូលផ្ទាល់របស់ខេត្ត ក្រុង ។

22. ចំពោះខេត្តបាត់ដំបង និងខេត្តសៀមរាប គំរោងចំណាយត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយរបស់ស្រុកដំបងបាត់ និងស្រុកសៀមរាប ដែលខេត្តត្រូវបែងចែក (តាមរូបមន្តបែងចែកចំណាយឆ្នាំ ២០០៥) និងធ្វើប្រតិភូកម្មជូនស្រុក ដើម្បីអនុវត្តជាអាណាប័កផ្ទេរសិទ្ធិ ។

23. គំរោងចំណូល ចំណាយថវិកាខេត្ត ក្រុងត្រូវបានកែសំរួលបំពេញបន្ថែមតាមទំរង់ដូចមានភ្ជាប់មកជាមួយ និងសារាចរណែនាំនេះ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលខេត្ត ក្រុងទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង.............

ឧបសម្ព័ន្ធទី១

ការគ្រប់គ្រងឆ្នាំ ២០០៦

តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	អនុកថាខ័ណ្ឌ	ការរាយមុខចំណូល (តាមមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០០៥			គំរោងឆ្នាំ ២០០៦
					ច្បាប់ដើមឆ្នាំ	អនុវត្តឆមាសទី១	ចាំន់ស្មានឆ្នាំ	

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
អ្នកធ្វើតារាង

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាប្រធានមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ការគ្រប់គ្រងឆ្នាំ ២០០៦

តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	ការវាយមុខចំណូល (តាមមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០០៥: ច្បាប់ដើមឆ្នាំ	ការគ្រប់គ្រងឆ្នាំ ២០០៥: អនុវត្តឆមាសទី១	ការគ្រប់គ្រងឆ្នាំ ២០០៥: ប៉ាន់ស្មានឆ្នាំ	គំរោងឆ្នាំ ២០០៦
				ប្រភេទទី១: ពន្ធ និង អាករ				
10				**ជំពូក១០: ពន្ធ និង អាករ**				
	08			ពន្ធលើដីធ្លីមិនបានប្រើប្រាស់				
11				**ជំពូក១១: ពន្ធលើបេតិកភ័ណ្ឌ**				
	01			ពន្ធប្រថាប់ត្រា				
12				**ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវាកម្ម**				
	03			ពន្ធប៉ាតង់				
	04	02		អាករពិសេស: របបនៃការនាំចូល				
	05			ពន្ធស្នាក់នៅ				
	08			អាករលើតំលៃបន្ថែម: របបនាំចូល				
		01		សហគ្រាសប្រេងឥន្ធនៈ				
		02		សហគ្រាសដទៃទៀត				
	06			ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ				
	07			អាករសំរាប់បំភ្លឺសាធារណៈ				
	09			អាករលើការស្នាក់នៅ				
13				**ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស**				
	01			ពន្ធ និង អាករគយពីការនាំចូល				
		01		ពន្ធគយពីការនាំចូល				
		03		កំរៃយកមុនលើការងារគយក្នុងការនាំចូល				
		04		ពន្ធគយលើផលិតផលប្រេងកាត				
		05		អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់				
	03			ការផាកពិន័យរបស់គយ				

បញ្ជាក់: ចំពោះខេត្ត ក្រុងទាំងឡាយណាដែលមានដូចមុខចំណូលខាងលើ ត្រូវគ្រោងបញ្ចូលទៅក្នុងតារាង ឧបសម្ព័ន្ធទី ១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី២

ការគ្រប់គ្រងឆ្នាំ ២០០៦

តារាងសរុបចំណាយថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

ជំពូក	ប្រការ	គណនី	អនុគណនី	ការរាយមុខចំណាយ (តាមមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០០៥			គំរោងឆ្នាំ ២០០៦
					ច្បាប់ដើមឆ្នាំ	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥

អ្នកធ្វើតារាង

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
សលាកបត្រ៦

ខេត្ត ក្រុង:...........

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាងសរុបនៃបុគ្គលិក, បៀវត្ស និង ប្រាក់បំណាច់

បុគ្គលិក / អង្គភាព	បៀវត្ស សរុប	ចំនួនបុគ្គលិក សរុប	ប្រភេទបុគ្គលិកដែលមានសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦					បុគ្គលិក អណ្តែត	បុគ្គលិក ជាប់កិច្ចសន្យា
			បុគ្គ.អចិន្ត្រៃយ៍សរុប	ប្រភេទ"ក"	ប្រភេទ"ខ"	ប្រភេទ"គ"	ប្រភេទ"ឃ"		
សរុប									
ខុទ្ទកាល័យ									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
....									
....									
....									
....									
....									
....									

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សលាកប័ត្រ២

ខេត្ត ក្រុង:............

ការគ្រប់គ្រងឆ្នាំ ២០០៦

អសន្ធារឹម: ជំពូក៦១ ~ ប្រការ០១ ~ កថាខ័ណ្ឌ០១

អសង្ហារឹម / អង្គភាព	សរុប	អសង្ហារឹមប្រើប្រាស់ក្នុងរដ្ឋបាល				អសង្ហារឹមប្រើប្រាស់ក្នុងវាសនដ្ឋាន			
		០១.ថ្លៃឈ្នួល	០២.ការរៀបចំ	០៣.ទឹក	០៤.អគ្គិសនី	០១.ថ្លៃឈ្នួល	០២.ការរៀបចំ	០៣.ទឹក	០៤.អគ្គិសនី
សរុប									
ខុទ្ទកាល័យ									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
....									
....									
....									
....									

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សលាកបត្រ៣

ខេត្ត ក្រុង:.........

ការគ្រប់គ្រងឆ្នាំ ២០០៦

ចលនវត្ថុ ~ សម្ភារៈ និងសម្ភារៈការិយាល័យ

ជំពូក១១ ~ ប្រករ០១ ~ កថាខ័ណ្ឌ០២ និង ០៤

អង្គភាព	សរុប	ចលនវត្ថុ និង សម្ភារៈ		ក្រដាសបោះពុម្ពនិងសម្ភារៈការិយាល័យ	
		ការទិញ	ការថែទាំ	ក្រដាសបោះពុម្ព	សម្ភារៈការិយាល័យ
សរុប					
ខុទ្ទកាល័យ					
អង្គភាព					
អង្គភាព					
អង្គភាព					
អង្គភាព					
អង្គភាព					
....					
....					
....					
....					
....					
....					

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សលាកប័ត្រ៤

ខេត្ត ក្រុង:............

ការគ្រប់គ្រងឆ្នាំ ២០០៦

រថយន្ត: ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០៧ វាក្យខ័ណ្ឌ០១ និង ០២

អង្គភាព	សរុប	ម៉ាករថយន្ត	ផ្លាកលេខ	ឆ្នាំទិញ	ចំនួនគ.មដែលត្រូវរត់	ការថែទាំ	ប្រេងឥន្ធនៈនិងប្រេងរំអិល
សរុប							
ខុទ្ទកាល័យ							
អង្គភាព							
អង្គភាព							
អង្គភាព							
អង្គភាព							
អង្គភាព							
....							
....							
....							
....							

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សលាកបត្រ៥

ខេត្ត ក្រុង:................

ការគ្រប់គ្រងឆ្នាំ ២០០៦

ចំណាយទូទាត់សោហ៊ុយៈ ជំពូក១១ ~ ប្រការ០២

ប្រភេទបេសកកម្ម អង្គភាព	សរុប	បេសកកម្មនៅក្នុងមណ្ឌល ឧបត្ថម្ភរបបបេសកកម្ម	បេសកកម្មអន្តរមណ្ឌល សោ.ដឹកជញ្ជូន	សោ.ហូបចុក	សោ.បេសកកម្ម	សោ.ស្នាក់នៅ	បេសកកម្មក្រៅប្រទេស សោ.ដឹកជញ្ជូន	សោ.ហូបចុក	សោ.បេសកកម្ម	សោ.ស្នាក់នៅ	សោ.ផ្សេងៗ
សរុប											
ខុទ្ទកាល័យ											
អង្គភាព											
អង្គភាព											
អង្គភាព											
អង្គភាព											
អង្គភាព											
....											
....											
....											
....											
....											
....											
....											

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៥៥៧ ឧរថ. ទស. ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ការចេញលិខិតអនុញ្ញាតដំណើរការផលិតកម្ម-អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត របស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-បានឃើញប្រកាសលេខ ៣១៩ ឧរថ. ទស. ប្រក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទីប្រជុំជនខេត្ត-ក្រុង ក្រោមឥណទានធនាគារពិភពលោក
- យោងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល
- យោងតំរូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ១: មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុងទាំងអស់ ក្នុងការចេញលិខិតអនុញ្ញាតឱ្យទៅ រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ ដើម្បីធ្វើការសាងសង់ ការស្តារហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកប្រព័ន្ធផលិតកម្ម-និងដំណើរការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតគ្រប់ប្រភេទ ចាំបាច់ត្រូវស្នើសុំគោលការណ៍ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាមុន។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: នាយកដ្ឋានទឹកស្អាតមានតួនាទី តាមដានត្រួតពិនិត្យការអនុវត្តន៍ប្រកាសនេះ និង ធ្វើរបាយការណ៍ទៀងទាត់ជូនឯកឧត្តមរដ្ឋមន្ត្រី។

ប្រការ៣: ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវអនុវត្តតាមសេចក្តីសំរេចនេះឱ្យ បានម៉ឺងមាត់បំផុត។ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុងទាំងអស់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខកខាន ឬ ល្មើសនឹងប្រការ ឬ នីតិវិធីណាមួយនៃប្រកាសនេះ សំដៅទទួលបាននូវប្រសិទ្ធិភាពខ្ពស់។

ប្រការ៤: ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ចំលងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត-ក្រុង...................................
-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង.............................
- អង្គភាពគ្រប់គ្រងគំរោងខេត្ត-ក្រុង ពាក់ព័ន្ធគំរោង" ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ កាលប្បវត្តិ

ស៊ុយ_សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ ២៣០ ប្រក ប.ស្ក

រាជធានីភ្នំពេញ. ថ្ងៃទី ២៥ ខែ ៧ ឆ្នាំ២០០៥

ប្រកាស

ស្តីពី

ប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសំរេចក្នុងនាមក្រសួង ចំពោះគំរោងវិនិយោគ ជូនមន្ទីរបរិស្ថានខេត្ត-ក្រុង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៩ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស / រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃ ទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៥-១៦-១៧-១៨-១៩-២០-២១-២២-២៣-២៤-២៥-២៦-២៧-២៨-២៩-៣០-៣១-៣២-៣៣-៣៤-៣៥-៣៦-៣៧-៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគ ទាំង២៤ខេត្ត-ក្រុង ។

សំរេច

ប្រការ ១~ មន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងសំរេចទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ របស់គំរោងដែលស្នើឡើង ជាបុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចំរុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ឬក្រសួងស្ថាប័ន ដែលមានទំហំទុនវិនិយោគក្រោមពីរលាន (២.០០០.០០០) ដុល្លារ សហរដ្ឋអាមេរិក ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

ប្រការ ២~ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវតាមដាន ឃ្លាំមើល និងចាត់វិធានការអោយម្ចាស់គំរោងប្រត្តិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន ក្នុងដំណាក់ការសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តរួច ។

ប្រការ ៣~ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវបង្កើតក្រុមការងារជំនាញមួយ ដែលមានសមាសភាព ប្រធាន អនុប្រធានមន្ទីរ ប្រធានការិយាល័យទាំងអស់ និងមន្ត្រីជំនាញ ដើម្បីពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងដាក់ឆ្លងសុំយោបល់ពីមន្ទីរជំនាញពាក់ព័ន្ធនឹងអ្នកពាក់ព័ន្ធឯទៀត ។

ប្រការ ៤~ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់នូវឯកសារចំលងសំណុំឯកសារ គំរោងវិនិយោគជូនក្រសួងបរិស្ថាន នៅពេលដែលខ្លួនបានទទួលសំណុំឯកសារគំរោងវិនិយោគ ដែលត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយដែលបានទទួលការអនុញ្ញាតិជាគោលការណ៍អំពីអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ។

ប្រការ ៥~ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជូនក្រសួងបរិស្ថាន អំពីសកម្មភាពដែលបានអនុវត្តរបស់ខ្លួនទៅតាមករណីនិមួយៗ ដោយភ្ជាប់នូវឯកសារចម្លងនៃសំណុំលិខិតទាក់ទងនឹងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង ឬផែនការគ្រប់គ្រងបរិស្ថាន ។

ប្រការ ៦~ មន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធិអនុវត្តវិធានការច្បាប់ ចំពោះបទល្មើសរបស់ម្ចាស់គំរោងដែលបានអនុម័តរួច ហើយបានកំពុងដំណើរការ ដែលមានទឹកប្រាក់វិនិយោគក្រោមពីរលាន (២.០០០.០០០) ដុល្លារអាមេរិក ដែលល្មើសនឹងបទប្បញ្ញត្តិណាមួយនៃអនុក្រឹត្យ លេខ៧២ អនក្រ-បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

ប្រការ ៧. ក្នុងករណីដែលម្ចាស់គំរោងបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងប្រការ៦ ហើយដែលមន្ទីរបរិស្ថានខេត្ត-ក្រុង ពុំមានលទ្ធភាព ឬ សមត្ថភាពគ្រប់គ្រាន់ធ្វើការសន្និដ្ឋាន ចំពោះបទល្មើសទាំងនោះ ត្រូវរាយការណ៍ និងបញ្ជូនមកក្រសួងជាបន្ទាន់ដើម្បីសុំយោបល់ ។

ប្រការ ៨. មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តអោយបាន ត្រឹមត្រូវតាមខ្លឹមសារអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ប្រការ ៩. ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងការអនុវត្តការងារដែលបានទទួលប្រតិភូកម្មអំណាច ដូចបានចែងក្នុងប្រកាសនេះ។

ប្រការ ១០. នាយកដ្ឋានជំនាញរបស់ក្រសួង ត្រូវចាត់តាំងមន្ត្រីជំនាញចុះជួយកសាង និងពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានខេត្ត-ក្រុង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ប្រការ ១១. នាយកដ្ឋានជំនាញរបស់ក្រសួងត្រូវចាត់តាំងក្រុមជំនាញចុះធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសកម្មភាពអនុវត្តគំរោងនៅតាមខេត្ត-ក្រុង ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចការពារបរិស្ថាន។

ប្រការ ១២. អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ ប្រធានគ្រប់នាយកដ្ឋាន ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

ចម្លងជូនៈ

- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -គ្រប់ក្រសួង-ស្ថាប័ន
- -គ្រប់សាលាខេត្ត-ក្រុង
- -ដូចប្រការ ៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ការប្រគល់សិទ្ធិជូនមន្ទីរបរិស្ថានខេត្ត-ក្រុង ក្នុងការសំរេចចំពោះគំរោង
ដែលមានទុនវិនិយោគក្រោមពីរលានដុល្លារអាមេរិក
តារាងឧបសម្ព័ន្ធដែលថ្នាក់ខេត្ត-ក្រុងត្រូវអនុវត្ត
ចំណាត់ថ្នាក់គំរូឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ល.រ	ប្រភេទអាជីវកម្ម	ទំហំ
១	**វិស័យឧស្សាហកម្ម**	
១.១	មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង	≥ ៥០០ តោន/ឆ្នាំ
១.២	មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ	≥ ១.៥០០ លីត្រ/ថ្ងៃ
១.៣	មូលដ្ឋានផលិតដំណាប់ផ្លែឈើ	≥ ៥០០ តោន/ឆ្នាំ
១.៤	មូលដ្ឋានផលិតទឹកក្រូច	គ្រប់ទំហំ
១.៥	មូលដ្ឋានផលិតស្រា	គ្រប់ទំហំ
១.៦	មូលដ្ឋានផលិតស្រាបៀរ - អាល់កុល	គ្រប់ទំហំ
១.៧	មូលដ្ឋានផលិតទឹកស្អាត	≥ ១០.០០០ នាក់ប្រើប្រាស់
១.៨	មូលដ្ឋានផលិតបារី	≥ ១០.០០០ កញ្ចប់/ថ្ងៃ
១.៩	មូលដ្ឋានផលិត កែច្នៃសន្លឹកថ្នាំជក់	≥ ៣៥០ តោន/ឆ្នាំ
១.១០	មូលដ្ឋានផលិតស្ករស	≥ ៣.០០០ តោន/ឆ្នាំ
១.១១	មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ	≥ ៣.០០០ តោន/ឆ្នាំ
១.១២	មូលដ្ឋានផលិតទឹកត្រី - ស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ	≥ ៥០០.០០០ លីត្រ/ឆ្នាំ
១.១៣	រោងចក្រតម្បាញ - ជ្រលក់ពណ៌	គ្រប់ទំហំ
១.១៤	រោងចក្រកាត់ដេរមាន : បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌	គ្រប់ទំហំ
១.១៥	រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី	គ្រប់ទំហំ
១.១៦	រោងចក្រផលិតអេប៉ុង - កៅស៊ូមូស	គ្រប់ទំហំ
១.១៧	រោងចក្រក្ដារបន្ទះ	≥ ១០០.០០០ម³/ឆ្នាំ [illegible]
១.១៨	មូលដ្ឋានផលិតគ្រឿងសម្អាង	≥ ១.០០០ម³/ឆ្នាំ [illegible]

១.១៩	រោងចក្រអារឈើ	≥ ៥០.០០០ម៣/ឆ្នាំឈើមូល
១.២០	រោងចក្រផលិតក្រដាស	គ្រប់ទំហំ
១.២១	រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស	គ្រប់ទំហំ
១.២២	រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ	≥ ៥០០ តោន/ឆ្នាំ
១.២៣	រោងចក្រកៅស៊ូក្រែប	≥ ១.០០០ តោន/ឆ្នាំ
១.២៤	រោងចក្រផលិតអាគុយ និងថ្មពិល	គ្រប់ទំហំ
១.២៥	រោងចក្រគីមី	គ្រប់ទំហំ
១.២៦	រោងចក្រផលិតជីគីមី	≥ ១០.០០០ តោន/ឆ្នាំ
១.២៧	រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត	គ្រប់ទំហំ
១.២៨	រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ	គ្រប់ទំហំ
១.២៩	រោងចក្រផលិតម្សៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក	គ្រប់ទំហំ
១.៣០	ស្ថានីយប្រេងឥន្ធនៈ	≥ ២០.០០០ លីត្រ
១.៣១	រោងចក្រផលិតកែវ - ដបគ្រប់ប្រភេទ	គ្រប់ទំហំ
១.៣២	មូលដ្ឋានផលិតឥដ្ឋក្បឿង	≥ ១៥០.០០០ ដុំ/ខែ
១.៣៣	មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ	≥ ៩០.០០០ ដុំ/ខែ
១.៣៤	រោងចក្រផលិតថ្មស្អូយ	គ្រប់ទំហំ
១.៣៥	មូលដ្ឋានផលិតគ្រឿងសំណង់បេតុង	≥ ៩០០ តោន/ខែ
១.៣៦	រោងចក្រផលិតខ្លាញ់គោ-ប្រេងម៉ាស៊ីន	គ្រប់ទំហំ
១.៣៧	រោងចក្រផលិតគ្រឿងយន្ត	គ្រប់ទំហំ
១.៣៨	រោងចក្រតំឡើងគ្រឿងយន្ត	គ្រប់ទំហំ
១.៣៩	សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា	គ្រប់ទំហំ
១.៤០	រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - លួសបន្លា - សំណាញ់	≥ ៣០០ តោន/ខែ
១.៤១	រោងចក្រស្លលោហៈគ្រប់ប្រភេទ	គ្រប់ទំហំ

១.៤២	រោងចក្រផលិតសំឡី	≥ ១៥ តោន/ខែ
១.៤៣	រោងចក្រផលិតចំណីសត្វ	≥ ១០.០០០ តោន/ឆ្នាំ
២	**វិស័យកសិកម្ម**	
២.១	អាជីវកម្មព្រៃគប់	≥ ៥០០ ហ.ត ដល់ ៩០០ ហ.ត
២.២	ផ្ទៃដីដែលមានព្រៃឈើ	≥ ៥០០ ហ.ត ដល់ ៩០០ ហ.ត
២.៣	ផ្ទៃដីកសិ-ឧស្សាហកម្ម	≤៩.០០០ ហ.ត
២.៤	ប្រព័ន្ធស្រោចស្រព	≥ ៥.០០០ ហ.ត
២.៥	ប្រព័ន្ធដោះទឹក	≥ ៥.០០០ ហ.ត
២.៦	ផែនេសាទ	គ្រប់ទំហំ
៣	**វិស័យទេសចរណ៍**	
៣.១	តំបន់ទេសចរណ៍ (ក្រៅពីតំបន់ការពារធម្មជាតិ)	≥ ៥០ ហ.ត
៤	**ហេដ្ឋារចនាសម្ព័ន្ធ**	
៤.១	ការអភិវឌ្ឍន៍ទីក្រុង	គ្រប់ទំហំ
៤.២	ភោជនីយដ្ឋាន	≥ ៥០០ កៅអី
៤.៣	សំណង់សណ្ឋាគារ	≤១០០ បន្ទប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧០៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែកក្កដាឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហូលី ខបភើរេសិន**

HOLY CORPORATION Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2485 /05E** ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក JEONG CHUNG WON ប្រធានក្រុមប្រឹក្សាភិបាល
លោក KIM WON KEUN អភិបាល
លោក SHIN DONG SIK អភិបាល
លោក KIM KYEONG YEON អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៧ ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត មជ្ឈមណ្ឌលកីឡា
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤០ ពណ.នតក

ភ្នំពេញថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហា នូ ជី អ៊ីមផត អិចផត គ្រុប**

HA NU CHI IMPORT EXPORT GROUP Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2490/05E ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក WANG , PO - JEN

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥អឺ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ

-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក័រជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងថែទាំទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

ក្រសួងពាណិជ្ជកម្ម

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រតិភូរាជរដ្ឋាភិបាល

កឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៤៦ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត**
PHNOM PENH SUPPLY COMPANY LIMITED
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Inv. 958/05E ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក PORNSAKDI NOPPORNPROM ប្រធានក្រុមប្រឹក្សាភិបាល
លោក CHARNCHAI NOPPORNPROM អភិបាល
៣- ដើមទុនក្រុមហ៊ុន : ចំនួន ១.000.000 ដុល្លារអាមេរិក
៤- ទីស្នាក់ការក្រុមហ៊ុន : ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
៥- កម្មវត្ថុអាជីវកម្ម : -រោងចក្រផលិត ផលិតផលពីប្លាស្ទិក ដូចជាសំបកដបទឹកសុទ្ធ ស្បោងប្លាស្ទិក
៦- ចិរវេលា : ៧០ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គីម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តបន្ទាយមានជ័យ -មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៥៣ ពណ.នតក

ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តុនម៉ា អ៊ិនធើណេសិនណល ភីធីអ៊ី លីមីធីត**

TONMA INTERNATIONAL Pty Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2489 /05E , ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក KISVARDA ANTHONY PAUL ប្រធានក្រុមប្រឹក្សាភិបាល

លោក **ហូ សុជាតិ** អភិបាល

លោក RAVISANDRAN S/O SUPPIAH អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥១៨ ផ្លូវមុនីរ៉េត ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ

-ការជួល ការជួលជុល បញ្ញើរដាក់ឃ្លាំងនូវផលិតផលគ្រប់បែបយ៉ាងទំនិញសំភារៈ វត្ថុគ្រប់ប្រភេទមកពីគ្រប់ប្រភព -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-បើកគ្លីនិកព្យាបាលជំងឺ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក

-ជួសជុល សាងសង់ អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គ្រីន ១១ ខប**

GREEN 11 CORP.,LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7874 /05P ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សុខ សំណាង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១៦០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៥១ ផ្លូវលេខ ១៦៣ កែង ៤៧៨ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សិប្បកម្មផលិតទឹកបរិសុទ្ធ និង សេវាពាក់ព័ន្ធផ្សេងៗ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ

នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-បើកសាលារៀន

-សេវា[illegible] -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-[illegible] : [illegible]នីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត ។

៦- ចិរវេលា

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤៥ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេ.អេស.ភី**
A.S.P Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7872/05P ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **អាត់ សុផាត** ប្រធានក្រុមប្រឹក្សាភិបាល
លោក **សុត្រ ខន** អភិបាល
លោកស្រី **គង ស្រី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២២៥អា មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
- -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
- -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងទុវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួលដឹកសំភារៈទំនិញគ្រប់ប្រភេទ
- -ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- -បើកសាលារៀន
- -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
- -សេវាផ្សាយពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សាងសង់ ផ្លូវថ្នល់ អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

គីម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

លេខ ១៥៤៦ ពណ.នគត / ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស អិន. ម៉ាយក្រូ ហ្វាយណែន & អេហ្គ្រីខលឈើរ ឌីវេឡុបមេន**
SN. Micro Finance & Agriculture Development Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7873/05P ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **នន គឹមសុខណារ៉ុង** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី SUPAPORN THAVEESAKDE អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦៧៦ មណ្ឌល ១ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

៥- កម្មវត្ថុអាជីវកម្ម :
-ផ្តល់សេវាឥណទាន ផ្តល់សេវាសន្សំប្រាក់ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ តាមការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និង /ឬ អាជ្ញាធរពាក់ព័ន្ធ
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកតំណែជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៩៤៧ ពណ.នតក/

ភ្នំពេញថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វេនកូ ស៊ូព្រីម អេឃ្វីបមេន គ្រុប**

VENCO SUPREME EQUIPMENT GROUP Pte.Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2483 /05E** ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក LIM KIM BOON ប្រធានក្រុមប្រឹក្សាភិបាល

កញ្ញា **គាំង មុយឈួង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៦៥ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ... និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេច វ៉ាយ ត្រេឌីង & ត្រេនស្ព័ត ខូ អិលធីឌី**

H Y TRADING & TRANSPORT CO.,LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7853 /05P ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ផេង ហេង** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ទេព វុត្ថិយ៉ា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៨ B ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

